## មូលដ្ឋានរឹងមាំ (Probable Cause :PC)

PC ជាស្តង់ដារមួយ មានប្រភពពីកំមុនឡូ និងត្រូវបានដាក់បញ្ចូលក្នុងវិសោធនកម្មទី៤ នៃកម្រងសិទ្ធិរបស់សហរដ្ឋអាមេរិក។ PC នេះតម្រូវនៅពេលកោះហៅអ្នកណាម្នាក់។[1] ការតម្រូវនេះ ជាការឆ្លើយតបនឹងការបារម្ភ ដែលថាចៅក្រម អាចលម្អៀងរដ្ឋាភិបាល ចេញដីកាស្រាវជ្រាវដើម្បីរកអ្វីមួយ។ នេះវាគ្រោះថ្នាក់ នៅពេលដែលមិនមានភស្តុតាងអ្វី ត្រូវបានរកឃើញក្រោយពីមានការស្រាវជ្រាវ។ ដូចនេះ ទ្រឹស្តី PC អាចជួយកម្រិតលើការបញ្ឈប់ និងស្រាវជ្រាវ (stop and search) ដោយប៉ូលីស ហើយបានក្លាយជាអាវុធចម្បងសម្រាប់តុលាការ ក្នុងការជួយការពារសិទ្ធិឯកជន (right to privacy) និងទប់ស្កាត់ប៉ូលីសពីការបំពានលើជនភាគតិច។

វិធាននេះ នឹងដាក់ទណ្ឌកម្មលើប៉ូលីសដោយស្វ័យប្រវត្តិ តាមរយៈការបដិសេធភស្តុតាង ដោយតុលាការ ទោះបីភស្តុតាងមានភាពរឹងមាំក្តី ដោយសារប៉ូលីសមិនបានបង្ហាញថាមាន PC ដើម្បីការស្រាវជ្រាវនោះ។ នេះ កើតមានជាពិសេស ក្នុងប្រព័ន្ធតុលាការសហរដ្ឋអាមេរិក ដែលអនុញ្ញាតឲ្យមានការបដិសេធភស្តុតាង តាមទ្រឹស្តីផ្លែឈើនៃដើមឈើពុល (doctrine of the fruit of the poisoned tree)។

---

[1] No warrants shall issue but upon probable cause, supported by oath or affirmation.